# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ: ០៤៨/១៤ ស.ខ.ក.ក.

## គោរពជូន

## ឯកឧត្តម ប៉ា សុជាតិវង្ស

## អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

**កម្មវត្ថុ:** ជូនដំណឹងស្តីអំពីការដង្ហែញត្តិទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថានទូតប្រទេសអាស៊ាន ប្រចាំព្រះរាជាណាចក្រកម្ពុជា

តបតាមកម្មវត្ថុខាងលើ ដោយពុំមានការឆ្លើយតបជាផ្លូវការពីក្រសួងការបរទេសខ្មែរក្នុងការបញ្ជាក់ថា តើស្ថានទូតវៀតណាម ឬ រដ្ឋាភិបាលវៀតណាម បានទទួល ឬ មិនបានទទួលញត្តិរបស់ប្រជាពលរដ្ឋខ្មែរ និងភាពក្រអឺតក្រទមមើលងាយប្រជារាស្ត្រខ្មែរពីសំណាក់រដ្ឋាភិបាលវៀតណាម ដោយបានប្រើប្រាស់មន្ត្រីស្ថានទូតវៀតណាម ប្រចាំកម្ពុជា និយាយច្រំដែលៗ ម្តងហើយម្តងទៀតថា មិនខ្វល់នឹងញត្តិ មិនខ្វល់នឹងការធ្វើបាតុកម្មរបស់ប្រជារាស្ត្រខ្មែរ និងព្រះសង្ឃខ្មែរនោះទេ ហើយនៅតែរក្សាជំហរមិនសុំទោសប្រជារាស្ត្រខ្មែរដដែលនោះ។ ដូច្នេះ សហគមន៍ខ្មែរកម្ពុជាក្រោម និង សម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ ដែលមាន iCambodia_យុវជន ដើម្បីប្រជាធិបតេយ្យ, យុវជនខ្មែរមហានគរ, ក្លឹបសំឡេងយុវជនខ្មែរ_អន្តរជាតិ, I Love Cambodia Hot News, យុវជនដើម្បីសន្តិភាព និង ចលនាយុវន ដើម្បីលទ្ធិប្រជាធិបតេយ្យ និងជាតិនិយម សូមអនុញ្ញាតជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា សហគមន៍ខ្មែរកម្ពុជាក្រោម និង សម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ នឹងរៀបចំធ្វើមហាបាតុកម្មចំនួន ០៣ថ្ងៃជាប់គ្នា គឺថ្ងៃទី១១-១២ និង១៣ ខែសីហា ឆ្នាំ២០១៤ ចាប់ពីម៉ោង ០៨ព្រឹករហូតដល់ម៉ោង ០៥ល្ងាច ជារៀងរាល់ថ្ងៃ។

ថ្ងៃទី១ - (១១.០៨.២០១៤) ម៉ោង ០៨ព្រឹក យើងខ្ញុំនឹងជួបជុំគ្នាប្រមាណ ១០០០រូប នៅសួនច្បារមុខវត្តបុទុមវតី (អតីតរោងអាយ៉ៃ) សម្តែងមតិរហូតដល់ម៉ោង ០១រសៀល ដង្ហែញត្តិទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទៅស្ថានទូតប្រទេសភូមា និងសាធារណរដ្ឋប្រជាមានិតឡាវ រួចដង្ហែក្បួនទៅស្ថានទូតវៀតណាម ដើម្បីទទួលចម្លើយអំពីការទទួលញត្តិរបស់យើងខ្ញុំ និងរំសាយនៅម៉ោង ៥ល្ងាច។

ថ្ងៃទី២ - (១២.០៨.២០១៤) ម៉ោង ០៨ព្រឹក យើងខ្ញុំនឹងជួបជុំគ្នាប្រមាណ ១០០០រូប នៅសួនច្បារមុខវត្តបុទុមវតី (អតីតរោងអាយ៉ៃ) សម្តែងមតិរហូតដល់ម៉ោង ០១រសៀល ដង្ហែញត្តិទៅស្ថានទូតប្រទេសសិង្ហបុរី ប្រុយណេ ថៃឡង់ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី រួចដង្ហែក្បួនទៅស្ថានទូតវៀតណាម ដើម្បីទទួលចម្លើយអំពីការទទួលញត្តិរបស់យើងខ្ញុំ និងរំសាយនៅម៉ោង ៥ល្ងាច។

ថ្ងៃទី៣ - (១៣.០៨.២០១៤) ម៉ោង ០៨ព្រឹក យើងខ្ញុំនឹងជួបជុំគ្នាប្រមាណ ១០០០រូប នៅសួនច្បារមុខវត្តបុទុមវតី (អតីតរោងអាយ៉ៃ) សម្តែងមតិរហូតដល់ម៉ោង ០១រសៀល ដង្ហែញត្តិទៅស្ថានទូតប្រទេសហ្វីលីពីន រួចដង្ហែក្បួនទៅស្ថានទូតវៀតណាម ដើម្បីទទួលចម្លើយអំពីការទទួលញត្តិរបស់យើងខ្ញុំ និងរំសាយនៅម៉ោង ៥ល្ងាច។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និងជួយចាត់វិធានការការពារសន្តិសុខសណ្តាប់ធ្នាប់ដល់ក្បួនបាតុកម្មរបស់យើងខ្ញុំដោយអនុគ្រោះ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ៕

រាជធានីភ្នំពេញ, ថ្ងៃចន្ទ ទី០៤ ខែសីហា ឆ្នាំ២០១៤
នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា
អតីតសមាជិកព្រឹទ្ធសភា

ព័ត៌មានបន្ថែម សូមទាក់ទង:
០១២ ៩០៨ ៨៨២
០៧៧ ៥២៩ ២៦២
០៧៧ ៣៧៣ ៧៣៦


ទីស្នាក់ការ: ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី
ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា; ទូរស័ព្ទលេខ: (៨៥៥) ៧៨ ៨៩៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦
អាសយដ្ឋានអ៊ីមែល: thachsetha13@gmail.com, kkcpressoffice@yahoo.com
Website: khmerkromngo.org; Facebook: khmerkkcommunity